# តិលមុដ្ឋិជាតក

ជាតកដ្ឋកថា ចតុត្ថោ ភាគោ ទំព័រ ៨- ១៤ ។

ព្រះញាណកោសល ញាណ– ឈឺន រៀបរៀង

នមោ ៣ ដង ។

សូមនមស្ការ ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់អង្គនោះ ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព ។

លំដាប់នេះ នឹងពណ៌នាអំពីបុគ្គលិកជាអរិយៈ ៤ ប្រភេទគឺ :

១- អាចារអរិយ

២- ទស្សនអរិយ

៣- លិង្គអរិយ

៤- បដិវេធអរិយ ។

មានសេចក្តីប្រែ នឹងអធិប្បាយដូចតទៅនេះ :

១- **អាចារអរិយៈ** ប្រែថា បុគ្គលអ្នកមានការប្រព្រឹត្តត្រឹមត្រូវ មានកិរិយាមារយាទល្អ អាកប្បកិរិយាថ្លៃថ្នូរ ឫកពាសមរម្យ ចរិយាខ្ពង់ខ្ពស់ ជាបរិនាយកអ្នកដឹកនាំគេ ឬសត្វពាហនៈ ដូចដំរីសេះជាអាទិ៍ ដែលគេហ្វឹកហ្វឺនបានបទ ដូចមានឧទាហរណ៍ថា “អ្នកនេះមាន អាកប្បកិរិយាល្អណាស់ ដំរីសេះនេះ បានបទល្អណាស់” ប៉ុណ្ណេះជាដើម នេះជា អាចារអរិយៈ។

៦- **ទស្សនអរិយៈ** ប្រែថា បុគ្គលជាមនុស្សជាតិនិងសត្វពាហនៈដែលមានរូបល្អ មានឥរិយាបថស្រគត់ស្រគំ គួរជ្រះថ្លា គួរក្រឡេកមើល ដូចឧទាហរណ៍ខាងលើដែរ នេះជាទស្សនអរិយៈ ។

ន័យដទៃទៀត ជនប្រុសស្រីណា បានឃើញព្រះសម្មុទ្ធព្រះបច្ចេកពុទ្ធ ឬបានឃើញពុទ្ធសាវកហើយ កើតសទ្ធាជ្រះថ្លា ចំពោះអរិយៈទាំងនោះ ការឃើញនោះឈ្មោះថាទស្សនានុត្តរិយៈ ការឃើញវិសេស ( អនុត្តរិយសូត្រ ភាណវារៈ ទំព័រ ៣២១, ឆកង្គុត្តរៈ ភាគ ៤២ – ទំព័រ ១០ ) ។ ការឃើញឥតទោស ។

៣- **លិង្គអរិយៈ** ប្រែថា បុគ្គលដែលមានឋានៈត្រឹមណាក៏ដោយ ទោះជាគ្រហស្ថ ឬបព្វជិត មានសីលបរិសុទ្ធខ្លះ សៅហ្មងខ្លះ គ្រាន់តែមានសម្លៀកបំពាក់ពណ៌លឿង ស កាន់យកភេទជាសមណៈគួរជ្រះថ្លា គួរក្រឡេកមើល ដូចពុទ្ធបរិស័ទចំពូកខ្លះកាន់សីល ៨ – ១០ ស្លៀកពាក់សំពត់លឿង ស កោរសក់ កោរពុកមាត់ ពុកចង្កា ស្អាតបាត នេះជាលិង្គអរិយៈ ។

៤- **បដិវេធអរិយៈ** ប្រែថា ព្រះអរហន្តទាំងឡាយ មានព្រះសម្មុទ្ធជាដើម ដូចមានបាលីថា **អរិយោ វុច្ចន្តិ ពុទ្ធា ច បច្ចេកពុទ្ធា ពុទ្ធស្សាវកា ច** “ព្រះសព្វញ្ញុពុទ្ធក្តី ព្រះបច្ចេកពុទ្ធក្តី ពុទ្ធសាវកក្តី សុទ្ធតែជាអរិយៈទាំងអស់” នេះជាបដិវេធអរិយៈ ។

ប៉ុន្តែក្នុងទីនេះ អ្នកនិពន្ធមានបំណងនឹងដកស្រង់ចំពោះតែអាចារអរិយៈទី១ ខាងដើមមកសំដែងឲ្យពិស្តារ, ដូចមានបទសុភាសិតថា :

**អរិយោ អនរិយំ កុព្វំ　　　　យោ ទណ្ឌេន និសេធតិ**

**សាសនំ តំ ន តំ វេរំ　　　　ឥតិ នំ បណ្ឌិតា វិទូ ។**

ប្រែថា នរជនណាបានប្រហារគេ គឺដាល់តប់ទះ ឬវាយដោយរំពាត់ហើយហាមប្រាមចំពោះជនអ្នកដែលប្រព្រឹត្តអំពើអាក្រក់ពុំគាប់ប្រសើរ នរជនអ្នកហាមប្រាមនោះ បានឈ្មោះថា អាចារអរិយៈ ពាក្យប្រដៅរបស់លោកនោះចាត់ជាឱវាទ ពាក្យនោះមិនមែនជាវេរាឡើយ អ្នកប្រាជ្ញតែងស្គាល់ច្បាស់នូវនរជននោះ ដូច្នេះឯង ។

មិនតែប៉ុណ្ណោះសោត ទោះទាំងវាចារបស់មាតាបិតាគ្រូអាចារ្យដែលពោលបោកបោះ បញ្ឆោះបញ្ឆើដូចពាក្យថា អ្នកឯងត្រូវក្របីវ៉ែធ, អ្នកឯងត្រូវចោរសម្លាប់ជាដើម ដៅទៅរក បុត្តធីតា ឬកូនសិស្សដែលមានកំហុស ប៉ុន្តែចិត្តរបស់លោកនៅមានមេត្តាទន់ភ្លន់ចំពោះ ជីវភាពនិងប្រយោជន៍ដែលផ្តល់នូវសេចក្តីចម្រើនតទៅមុខ របស់បុត្តធីតា ឬកូនសិស្សនោះៗ ជាដរាប ។ វាចាដែលបោកបោះនោះមិនហៅថា “ផរុសវាចា” ឡើយ ( អដ្ឋកថាមង្គលសូត្រ, វិន័យកថា ទំព័រ ៧២ – ៩៣ ។ ) ហើយមាតាបិតា និងគ្រូទាំងនោះគង់បានឈ្មោះថា អាចារ-អរិយៈដោយពិត ។ ឧទាហរណ៍ ដែលនាំមកប្រៀបធៀបនេះ ស្របគ្នានឹងបទសុភាសិតខាង ដើមនោះដែរ ។

បន្ទាប់អំពីនេះ សូមសំដែងជាតកដែលជាបុព្វហេតុនៃអរិយបុគ្គលទាំង ៤ ដូចមាន សេចក្តីថា៖

កាលសម្តេចព្រះសុគតជាម្ចាស់ទ្រង់ធរមាននៅឡើយ ព្រះអង្គទ្រង់ប្រថាប់នៅនាវត្ត ជេតពន ជាអារាមរបស់អនាថបណ្ឌិតសេដ្ឋី ទៀបក្រុងសាវត្ថី ទ្រង់ប្រារព្ធនឹងភិក្ខុ ១ រូប ដែល ជាអ្នកឆាប់ក្រោធ ។

សេចក្តីថា មានភិក្ខុ ១ រូបជាអ្នកឆាប់ក្រោធ ជាអ្នកមានចិត្តក្រៀមក្រំ គ្រាន់តែគេ និយាយលើសលោះបន្តិចបន្តួច ក៏ជេរប្រទេចគេ តែងតែប្រមូលទោសក្រោធមិនសមហេតុ ផល ធ្វើឲ្យជាក់ស្តែងដូចបុរាណថា ចាបផ្សែងពូតជាដុំ ។ ថ្ងៃមួយ ភិក្ខុច្រើនរូប អង្គុយប្រជុំគ្នា សន្ទនាថា អាវុសោទាំងឡាយ! ភិក្ខុជាអ្នកក្រោធ ១ រូបនោះ មានចិត្តក្រៀមក្រំតែងពោល ពាក្យរម៉ោករម៉ាំង ជេរប្រទេចគេរ ឮសូរប្រេះៗ ដូចអំបិលផ្ទុះក្នុងជើងក្រាន, ភិក្ខុនេះ បួសក្នុង ធម៌វិន័យដែលប្រដៅឲ្យអត់សង្កត់សេចក្តីក្រោធ, ឯខ្លួនលោកបែរជាឆាប់ក្រោធ មិនអាចនឹង អត់សង្កត់ទប់ទល់សេចក្តីក្រោធសោះ ។ ព្រះបរមសាស្តា ទ្រង់បានស្តាប់ពាក្យភិក្ខុទាំងនោះ ហើយ ទើបទ្រង់ឲ្យហៅភិក្ខុនោះមកត្រាស់សួរថា នែភិក្ខុ! ឮថាអ្នកឯងជាអ្នកឆាប់ក្រោធមែន ឬ? ។ ភិក្ខុនោះទទួលស្របថា ក្រាបទូលមែន ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា “ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុនេះមិនមែនជាអ្នកឆាប់ក្រោធតែក្នុងបច្ចុប្បន្ននេះទេ ពីមុនមក ភិក្ខុនេះធ្លាប់ជា អ្នកឆាប់ក្រោធដូច្នេះដែរ” លុះទ្រង់ត្រាស់ហើយ ក៏នាំអតីតនិទានថា :

**អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ .**

ក្នុងអតីតកាល មានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី ទ្រង់មានព្រះរាជបុត្រមួយអង្គ ព្រះនាម ព្រហ្មទត្តកុមារ ។

ទំនៀមក្សត្រពីបុរាណគ្រប់ៗ ព្រះអង្គសឹងជ្រាបច្បាស់ថា រាជកុមារសុទ្ធតែមានមានះរឹងត្អឹង ប៉ុន្តែជាអ្នកចេះអត់សង្កត់ត្រជាក់ក្តៅស្រេកឃ្លានបាន ត្រូវតែឲ្យចេះដឹងចរិយាសាស្ត្រ ចំណេះវិជ្ជា និងកិរិយាមារយាទសម្រាប់លោក ទ្រង់តែបញ្ជូនរាជបុត្ររបស់ខ្លួនៗ ឲ្យទៅរៀនក្នុងសំណាក់អាចារ្យទិសាបាមោក្ខដែលមានក្នុងប្រទេស បើមិនមានទេ ក៏បញ្ជូនឲ្យទៅប្រទេសក្រៅ ។ ព្រោះហេតុនោះ ព្រះបាទព្រហ្មទត្តទ្រង់ត្រាស់ហៅព្រះរាជបុត្ត ដែលមានអាយុ ១៦ ឆ្នាំមក ទ្រង់ប្រទានស្បែកជើងសង្រែក ១ គូ ឆត្រស្លឹក ១ ប្រាក់ ១ ពាន់កហាបណៈ ហើយផ្តាំថា “នែកូន! អ្នកត្រូវទៅកាន់ក្រុងតក្កសិលា ដើម្បីរៀនសិល្បសាស្ត្រចុះ” ។ ព្រះរាជកុមារក៏ទទួលព្រះរាជឱង្ការថា “សាធុ” ហើយសំពះលាមាតាបិតា ដើរចេញទៅតាមលំដាប់ ក៏បានដល់គ្រឹះស្ថានអាចារ្យនៅក្រុងតក្កសិលានោះ ។ កាលនោះ អាចារ្យទិសាបាមោក្ខទើបនឹងបង្រៀនពួកមាណពជាសិស្សរួចហើយ ក្រោកទៅអង្គុយនៅមាត់ទ្វារ ។ រីឯព្រះរាជកុមារបានឃើញអាចារ្យអង្គុយនៅមាត់ទ្វារហើយ ក៏ដោះស្បែកជើង តម្លោះឆត្រសំពះអាចារ្យ ហើយឈរនៅស្ងៀម ។ អាចារ្យបានជ្រាបនូវការលំបាកតាមផ្លូវ ក៏សង្គ្រោះព្រះរាជកុមារដោយអាគន្តុកកិច្ច ។ លុះព្រះរាជកុមារសោយរួចហើយសម្រាកកាយបន្តិច ទើបចូលទៅរកអាចារ្យ សំពះតាមកិច្ចគួរសម ។ អាចារ្យបានសួរថា : អ្នកមកពីនគរណា ? ។ ខ្ញុំមកពីនគរពារាណសី ។ អ្នកឯងជាបុត្រលោកណា ? ។ ខ្ញុំជាព្រះរាជបុត្ររបស់ព្រះបាទពារាណសី ។ អ្នកឯងមកដើម្បីអ្វី ? ខ្ញុំមកដើម្បីនឹងរៀនសិល្បសាស្ត្រ ។ អ្នកត្រូវការរៀនឈ្នួល ឬរៀនតាមធម្មតា ? ។ ខ្ញុំត្រូវការរៀនឈ្នួល ។ លុះជម្រាបហើយ ក៏យកប្រាក់ ១ ពាន់កហាបណ តម្កល់ទុកទៀបបាទមូលនៃលោកអាចារ្យ ។

មានសេចក្តីថា ក្នុងជំនាន់នោះ កូនសិស្សធម្មតាដែលឥតថ្លៃឈ្នួល រៀនបានតែវេលាយប់ ឯវេលាថ្ងៃធ្វើការជូនលោកអាចារ្យ ។ ចំណែកកូនសិស្សឈ្នួល រៀនបានទាំងយប់ទាំងថ្ងៃ ដូចជាបុត្រច្បងក្នុងគេហដ្ឋានដូច្នោះ ហេតុនោះ អាចារ្យទិសាបាមោក្ខ បង្រៀនព្រះ

រាជកុមារដោយសុភនក្ខត្តពេលវេលាល្អ ព្រះរាជកុមារក៏បានចេះដឹងឆាប់រហ័សទាន់ចិត្ត ។ មានថ្ងៃមួយក្រៅពីពេលរៀន ព្រះរាជកុមារនោះ ទៅងូតទឹកឯស្ទឹងជាមួយនឹងអាចារ្យ ។ កាលនោះ មានស្ត្រីចាស់ម្នាក់យកល្ងទៅហាលដើម្បីឲ្យស្ងួតសម្បក រួចអង្គុយឃ្លាំចាំមើល ។ ព្រះរាជកុមារបានឃើញល្ងនោះ ក៏នឹកចង់សោយ ទើបទៅកើបយកល្ង ១ ក្តាប់មកសោយ ។ ស្ត្រីចាស់បានឃើញហើយគិតថា កុមារនេះ ឥតរបបណាស់ ប៉ុន្តែគាត់មិននិយាយថាអ្វីឡើយ គាត់នៅស្ងៀម ។ លុះដល់ថ្ងៃជាគម្រប់ពីរគម្រប់បី ព្រះរាជកុមារធ្វើដូចមុនទៀត ស្ត្រីចាស់បានឃើញហើយ លើកដៃគក់ទ្រូងទ្រហោយំថា "អាចារ្យទិសាបាមោក្ខ នាំកូនសិស្សឲ្យមកប្លន់ខ្ញុំ" ។ អាចារ្យទិសាបាមោក្ខសួរថា "នៃយាយ! ដំណើរអ្វី?" ស្ត្រីចាស់ជំរាបថា "លោកម្ចាស់ កូនសិស្សរបស់លោកវាយកល្ង ដែលខ្ញុំកំពុងហាលមកទទួលទាន ក្នុងថ្ងៃនេះ ១ ក្តាប់ ពីម្សិលមិញ ១ ក្តាប់ ពីម្សិលម្ងៃ ១ ក្តាប់ បើទទួលទានតែយ៉ាងនេះ ល្ងរបស់ខ្ញុំនឹងវិនាសអស់ទៅទទេៗ ហើយ" ។

អាចារ្យឃាត់ថា នៃយាយ! កុំយំសោកឡើយចាំខ្ញុំសងថ្លៃជូន ។ ស្ត្រីចាស់ជំរាបថា ខ្ញុំពុំត្រូវការឲ្យសងថ្លៃទេ សុំឲ្យតែលោកគ្រូប្រដៅកូនសិស្ស កុំឲ្យធ្វើដូចមុនទៀតតែប៉ុណ្ណោះ ។

អាចារ្យទិសាបាមោក្ខនិយាយថា បើដូច្នោះ យាយឯងចាំមើលចុះ លុះថាហើយ ក៏ប្រើមាណពពីររូបឲ្យចាប់ព្រះរាជកុមារត្រង់ដៃទាំងសងខាងរួចហើយ យកបន្ទះឫស្សីវាយ ៣ ខ្វាប់ចំកណ្តាលខ្នងហាមប្រាមថា "នៃកុមារ! អ្នកកុំធ្វើដូចមុនទៀត" ។ ឯព្រះរាជកុមារនោះខ្វាល់ណាស់ ធ្វើព្រះនេត្រក្រឡៅសម្លក់មើលអាចារ្យ តាំងពីបាទជើងដរាបដល់ក្បាល ( ចងគំនុំទុក ) អាចារ្យក៏បានជ្រាបថា ព្រះរាជកុមារនេះ ខ្វាល់ចំពោះខ្លួនដែរ ។ លុះព្រះរាជកុមារបានរៀនចេះចប់វិជ្ជាហើយ ក៏ចងចិត្តថា ទៅអនាគតដ៏ខ្លី អញត្រូវតែសម្លាប់អាចារ្យនេះឲ្យបាន លុះគិតហើយជម្រាបថា "បពិត្រលោកអាចារ្យ បើកាលណាខ្ញុំបានទៅដល់មាតុភូមិហើយ បានសោយរាជ្យក្នុងក្រុងពារាណសី ខ្ញុំនឹងធ្វើលិខិតមកសូមអញ្ជើញលោកទៅជួបនឹងខ្ញុំ, ក្នុងកាលនោះ លោកត្រូវតែអញ្ជើញទៅ" ព្រះរាជកុមារធ្វើការរាក់ទាក់ ហាក់ដូចជាស្រឡាញ់អាចារ្យណាស់ រួចហើយសំពះដើរចេញទៅ ។ ក្រោយពីនោះមក ព្រះរាជកុមារបានវិលត្រឡប់មកដល់ក្រុងពារាណសី បានថ្វាយបង្គំមាតាបិតា សំដែងសិប្បៈដែលខ្លួនបាន

ចេះចាំថ្វាយព្រះរាជាៗ ទ្រង់សព្វព្រះរាជហឫទ័យ ដោយទ្រង់ឈ្វេងយល់ថា អញនឹងបាន ឃើញរាជកុមារនេះសោយរាជ្យ នៅវេលាដែលអញមានជីវិតរស់នៅ លុះទ្រង់ឈ្វេងយល់ហើយ ទ្រង់ព្រះរាជទានរាជសម្បត្តិ ចំពោះព្រះរាជកុមារក្នុងកាលនោះឯង ។ តាំងពីព្រះរាជកុមារបានសោយរាជ្យ ក៏រលឹកនូវទោសដែលអាចារ្យវាយ ៣ ខ្វាប់, ទ្រង់ព្រះពិរាធគិតថា "យើងនឹងសម្លាប់អាចារ្យសងពៀរវិញ" ទ្រង់បញ្ជាទូតឲ្យទៅអញ្ជើញអាចារ្យមក ។ ឯអាចារ្យទិសាបាមោក្ខគិតថា ព្រះរាជកុមារឋិតនៅក្នុងតរុណវ័យនៅឡើយ យើងពុំអាចពន្យល់ឲ្យយល់ហេតុផលបានទេ, គាត់ក៏មិនអញ្ជើញមក លុះព្រះរាជកុមារបានឋិតនៅក្នុងមជ្ឈិមវ័យទើបគិតថា វេលានេះ យើងអាចនឹងពន្យល់ព្រះរាជកុមារឲ្យយល់បាន គាត់ក៏អញ្ជើញមកហើយឈរនៅទៀបទ្វារព្រះរាជនិវេសន៍ រួចហើយឲ្យយកសេចក្តីក្រាបបង្គំទូលថ្វាយថា ឥឡូវនេះ អាចារ្យអញ្ជើញមកដល់ហើយ ។ ព្រះរាជាមានសេចក្តីត្រេកអរ ឲ្យអញ្ជើញព្រាហ្មណ៍ចូលមក គ្រាន់តែទ្រង់ទតឃើញព្រាហ្មណ៍មកដល់ ក៏កើតព្រះពិរោធមួយរំពេច ធ្វើព្រះនេត្រក្រឡៅ ទ្រង់ត្រាស់ហៅអាមាត្យមកប្រាប់ថា នែអ្នកទាំងឡាយ! ក្នុងថ្ងៃនេះ ត្រង់កន្លែងស្នាមដែលលោកអាចារ្យវាយខ្ញុំពីមុននោះ ឥឡូវនេះ កន្លែងនោះ វាចាប់ពើតឡើងវិញ, ប្រហែលជាលោកអាចារ្យគាត់នាំយកសេចក្តីស្លាប់មកជាមួយនឹងដួងព្រលឹងហើយមើលទៅ, គាត់នឹកថាអញមុខនឹងជាស្លាប់ ជីវិតរបស់អញនឹងមិនមានតទៅទៀតទេ, លុះទ្រង់ត្រាស់ហើយក៏ពោលពាក្យជាគាថាគំរាមដូច្នេះថា

**អជ្ជាបិ មេ តំ មនសិ យំ មំ ត្វំ តិលមុដ្ឋិយា**

**ពាហាយំ មំ គហេត្វាន លដ្ឋិយា អនុតាឡយិ**

**ននុ ជីវិតេ ន រមសិ យេនាសិ ព្រាហ្មណាគតោ**

**យំ មំ ពាហា គហេត្វាន តិក្ខត្តុំ អនុតាឡយិ**

ប្រែថា ម្នាលព្រាហ្មណ៍ លោកចាប់ខ្ញុំត្រង់ដើមដៃ លុះចាប់បានហើយ វាយខ្ញុំដោយបន្ទះឫស្សី ព្រោះតែល្ង ១ ក្តាប់ ការវាយនោះដក់នៅក្នុងចិត្តរបស់ខ្ញុំ ដរាបដល់សព្វថ្ងៃនេះ ។ ម្នាលព្រាហ្មណ៍ លោកមិនស្តាយជីវិតរបស់លោកទេឬ? ។

ពីមុនមិញ លោកចាប់ខ្ញុំត្រង់ដើមដៃ ហើយវាយ ៣ ខ្វាប់ ឥឡូវនេះ លោកអញ្ជើញមកកាន់សម្នាក់ខ្ញុំ សូមលោកទទួលនូវផលនៃការវាយនោះវិញ ។

លំដាប់នោះ អាចារ្យទិសាបាមោក្ខបានស្តាប់ព្រះសូរសៀងនៃព្រះបាទព្រហ្មទត្ត ដែលទ្រង់ព្រះពិរោធប៉ងនឹងដាក់ទណ្ឌកម្មចំពោះខ្លួនហើយ ទើបពោលពាក្យជាគាថាតបថា :

**អរិយោ អនរិយំ កុព្វំ ។**

**។ល។**

**ឥតិ នំ បណ្ឌិតា វិទូ ។**

សេចក្តីប្រែដូចខាងដើម ។

លុះចប់គាថាហើយ ក៏ពន្យល់ហេតុផលថា :

បពិត្រមហារាជ! សូមព្រះអង្គទ្រង់ជ្រាប ដូចទូលព្រះបង្គំបានក្រាបទូលនេះចុះ ព្រះអង្គពុំគួរចងពៀរក្នុងដំណើរវាយប្រដៅ ៣ ខ្វាប់នោះទេ ប្រសិនបើទូលព្រះបង្គំពុំបានប្រដៅព្រះអង្គ ពុំបានថ្វាយការសិក្សា ពុំបានហាមឃាត់អំពើអាក្រក់របស់ព្រះអង្គទេ នោះយូរៗ ទៅព្រះអង្គគង់ហ៊ានលួចនំចំណីទាំងឡាយមានផ្លែឈើជាដើម ពីរបស់តូចដល់របស់ធំ, ពីរបស់ទាបដល់របស់ខ្ពស់, ពីរបស់ថោកដល់របស់ថ្លៃ ហើយព្រះអង្គជាប់ព្រះរាជហឫទ័យក្នុងចោរកម្មសន្សឹមៗ ឡើងតាមលំដាប់ ដល់ហ៊ានកាត់ជញ្ជាំងរបងឃ្នង លួចយករបស់មានវិញ្ញាណឥតវិញ្ញាណទ្រង់នឹងទៅជាអ្នកមានកំហុស ព្រោះទោសលួច ហើយរាជបុរសគេនឹងចាប់ព្រះអង្គថាជាចោរនាំទៅថ្វាយព្រះមហាក្សត្រៗ នឹងទ្រង់ត្រាស់បង្គាប់ឲ្យធ្វើទណ្ឌកម្មសមគួរតាមទោសនោះៗ, កាលបើដូច្នោះ ធ្វើម្តេចឡើយព្រះអង្គនឹងបានសោយរាជសម្បត្តិនេះ ឥឡូវបែរជាទ្រង់បានទទួលព្រះរាជឥស្សរិយយសជាម្ចាស់ផែនដីនេះ មិនគឺបានដោយអាស្រ័យខ្ញុំព្រះអង្គទេឬ? ។ ឯអាមាត្យរាជបរិពារដែលទៅគាល់ជុំវិញ ក្រោយពីបានស្តាប់សេចក្តីដែលអាចារ្យទិសាបាមោក្ខដោះស្រាយ ហើយក៏បានក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព! ព្រះរាជឥស្សរិយយសរបស់ព្រះអង្គនេះ គឺជាសម្បត្តិរបស់លោកអាចារ្យពិតមែន ។ ព្រះរាជាក៏

ទ្រង់កត់ចំណាំនូវគុណរបស់អាចារ្យថា ពិតមែន ទើបទ្រង់ត្រាស់ថា បពិត្រលោកអ្នកមានគុណ! យើងសូមជូនឥស្សរិយយសទាំងអស់នេះ ចំពោះលោក សូមលោកទទួលរាជសម្បត្តិនេះចុះ ។ អាចារ្យប្រកែកថា បពិត្រមហារាជ! ខ្ញុំព្រះអង្គ ពុំត្រូវការដោយរាជសម្បត្តិនេះទេ ខ្ញុំព្រះអង្គគ្រាន់តែទូលសារស័ព្ទ សូមទ្រង់ជ្រាបតែប៉ុណ្ណេះ ។ ព្រះរាជាទ្រង់បញ្ជូនរាជទូតទៅកាន់ក្រុងតក្កសិលា ឲ្យនាំគ្រួសាររបស់លោកអាចារ្យមកជួបជុំ ទ្រង់នឹងព្រះរាជទានឥស្សរិយយស ដ៏ធំគឺតែងតាំងលោកអាចារ្យក្នុងឋានន្តរជារាជបុរោហិត លើកតម្កើងបុរោហិតនោះ ទុកដូចជាបិតារបស់ព្រះអង្គៗ ទ្រង់ឋិតនៅក្នុងឱវាទនៃបុរោហិតសព្វៗ កាល ទ្រង់សន្សំបុណ្យមានធ្វើទានជាដើម លុះអវសាននៃព្រះជន្ម ទ្រង់បានទៅកើតក្នុងស្ថានទេវលោក ។

លុះព្រះបរមសាស្តា ទ្រង់សំដែងធម៌ទេសនាប្រកាសសច្ចធម៌ទាំង ៤ ប្រការចប់ហើយ ភិក្ខុអ្នកក្រោធនោះ បានប្រតិស្ឋានទៅក្នុងអនាគាមិផល ពុទ្ធបរិស័ទដ៏សេសបានដល់នូវសោតាបត្តិផលខ្លះ សកទាគាមិផលខ្លះ តាមសមគួរដល់វាសនាបារមីរៀងៗ ខ្លួន ។ ឯព្រហ្មទត្តរាជកុមារ ក្នុងកាលនោះ គឺភិក្ខុអ្នកក្រោធក្នុងកាលឥឡូវនេះ ។ អាចារ្យទិសាបាមោក្ខ គឺអង្គតថាគតនេះឯង ។

មុននឹងបញ្ចប់ជាតកនេះ សូមសំដែងពីអរិយស័ព្ទដែលប្រែថា ប្រសើរ ប្រពៃ ត្រឹមត្រូវ វិសេសវិសាល ដើម្បីពង្រីកសេចក្តីឲ្យរីកទូលាយឡើង ត្បិតអរិយស័ព្ទជាបទផ្ទុយនឹងអនរិយស័ព្ទ ប្រែថា មិនប្រសើរ មិនប្រពៃ មិនត្រឹមត្រូវ មិនវិសេសវិសាល បន្តិចសិន ទើបបញ្ចប់ជាតកជាខាងក្រោយ ព្រោះអរិយស័ព្ទនឹងអនរិយស័ព្ទនេះ គ្រាន់តែជាបទវិសេសគុណដោយនាមស័ព្ទ ឬទោះនាមស័ព្ទនោះ ជាធម៌អាថ៌ ឬជាបុគ្គលក៏ដោយ ដូចន័យក្នុងប្រយោគថា :

**ទ្វេ មេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា កតមេ ទ្វេ យោចាយំ កាមេសុ កាមសុខល្លិ-កានុយោគោ ហីនោ គម្មោ បោថុជ្ជនិកោ អនរិយោ អនត្ថសញ្ហិតោ ។ យោចាយំ អត្តកិលមថានុយោគោ ទុក្ខោ អនរិយោ អនត្ថសញ្ហិតោ ។** ( ធម្មចក្កប្បវត្តនសូត្រ ភាណវារៈ ទំព័រ ៦៨ )

ប្រែថា ម្នាលភិក្ខុទាំងឡាយ លាមកធម៌ទាំងពីរប្រការនេះ បព្វជិតមិនត្រូវសេពគប់ឡើយ ។ លាមកធម៌ទាំងពីរប្រការ តើអ្វីខ្លះ? គឺការប្រព្រឹត្តរឿយៗ នូវកាមសុខ ក្នុងវត្ថុកាម

មានរូបជាដើម ជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយៈ មិនមានប្រយោជន៍ ១ ការប្រព្រឹត្តរឿយៗ នូវអំពើថោកទាប ធ្វើខ្លួនឲ្យលំបាកមានប្រព្រឹត្តសុនខវត្តជាដើម ជារបស់នាំមកនូវទុក្ខ មិនប្រសើរ មិនមានប្រយោជន៍ ១ ។ នេះ អនរិយសព្ទ ពិសេសដោយបទ កាមសុខល្លិកានុយោគៈ និងអត្តកិលមថានុយោគ :

មួយទៀត មានប្រយោគថា **អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ** ប្រែថា មគ្គមានអង្គ៨ប្រការ មានសម្មាទិដ្ឋិជាដើម ជារបស់ប្រសើរ ជាអរិយធម៌ នេះអរិយសព្ទពិសេស ដោយមគ្គមានអង្គ ៨ ប្រការដូច្នេះ ។ ប្រយោគទាំងពីរនេះចង្អុលឲ្យឃើញថា អរិយស័ព្ទ ជាបទវិសេសដោយធម៌អាថ៌ ។

ឯអរិយស័ព្ទពិសេសដោយបុគ្គលដូចមានបទសុភាសិតថា :

**ពុទ្ធា បច្ចេកពុទ្ធា　　　　អរថោបិ ពុទ្ធសាវកា**

**ក្លេសារីហិ អបេតត្តា　　　　សព្វេ អរិយសម្មតា ។**

( អរិយវិសសូត្រ ភាណវារៈ ទំព័រ ៣០០ )

ប្រែថា ព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវកទាំងឡាយ ឈ្មោះថា អរិយៈ ព្រោះឃ្លាតចាកសត្រូវ គឺកិលេស ។

នេះចង្អុលឲ្យឃើញថា អរិយស័ព្ទជាបទវិសេសដោយបុគ្គល នៅមានឧទាហរណ៍ដទៃទៀតថា :

**ទ្វេមា ភិក្ខវេ បរិយេសនា អនរិយា ច បរិយេសនា អរិយា ច បរិយេសនា** ( បាសរាសិ-សូត្រ ភាគ. ២១ ទំព័រ ១២៨ )

ប្រែថា ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមានពីរប្រការគឺ អនរិយបរិយសនា ការស្វែងរកខុសទំនងមិនប្រសើរ មានការស្វែងរកជាតិជរា ព្យាធិ មរណៈជាអាទិ ១, អរិយបរិយេសនា ការស្វែងរកខុសទំនងមិនប្រសើរ មានការស្វែងរកជាតិ ជរា ព្យាធិ មរណៈ ជាអាទិ ១, អរិយ-

បរិយេសនា ការស្វែងរកត្រូវទំនង ស្វែងរកប្រសើរ មានការស្វែងរកមោក្ខធម៌ ព្រះនិព្វានជាទីបំផុត នៃជាតិជរា ព្យាធិ មរណៈ ១ ។

នេះចង្អុលឲ្យឃើញថា អនរិយសព្ទ និងអរិយសព្ទទាំងពីរនេះជាបទវិសេសដោយធម៌អាថ៌ ។ ព្រោះមានន័យជាគោលអាងច្រើនបែបយ៉ាងនេះ ទើបពួកបណ្ឌិតជនទាំងសាកលគេនិយមប្រើអរិយសព្ទនេះ, ស្ទើរតែគ្រប់ប្រយោគ គ្រប់ភាសាជាតិនៃប្រទេសនោះៗ ដូចមានពាក្យថា "លោកអ្នកនោះជាអរិយបុគ្គល អរិយសាវក អរិយជនអរិយធម៌ អរិយសីល អរិយវោហារ អនរិយវោហារ អរិយទ្រព្យ អារ្យប្រទេស អារ្យភូមិ ។ល។ ជាគុណបទ និងនាមសព្ទ ដូចមានហើយនោះ ។

ពាក្យផ្ទួនថា :

ក. បុគ្គលមានធម៌ខ្ពស់ប្រសើរលើសគេគឺ បានដល់នូវសោតាបត្តិមគ្គជាដើម ដរាបដល់អរហត្តផល ឈ្មោះថា អរិយបុគ្គល ឬមួយអ្នកប្រព្រឹត្តល្អខ្ជាប់ខ្ជួនក្នុងនិច្ចសីល ឧបោសថសីល មិនមានសៅហ្មង ទាំងមានកិរិយា មារយាទមិនឆ្គាំឆ្គង ទាស់ខុសក្នុងពុទ្ធប្បញ្ញត្តិ នឹងរាជប្បញ្ញត្តិ ផ្លូវលោក ផ្លូវធម៌ ក៏បានឈ្មោះថា អរិយបុគ្គលដែរ ។

ខ. អរិយសាវក អរិយជន សឹងមានគុណធម៌ដូចគ្នា មិនប្លែកគ្នាឡើយ ។

គ. អរិយធម៌ ធម៌ប្រសើរគឺ អដ្ឋង្គិកមគ្គទាំង ៨ ប្រការ មានសម្មាទិដ្ឋិជាអាទិ៍ ឬធម៌របស់ព្រះអរិយៈ មានសុចរិតធម៌ជាដើម ។

ឃ. អរិយសីល សីលជាទីត្រេកអរនៃព្រះអរិយៈ ទោះនិច្ចសីលទាំង ៥ ឧបោសថសីលទាំង ៨ អតិរេកសីលទាំង ១០ ចតុប្បារិសុទ្ធិសីល ទាំង ៤ ក្តី សីលដែលមិនធ្លុះធ្លាយ មិនពព្រុស ពពាល សីលដែលអ្នកប្រាជ្ញសរសើរ សីលមិនជ្រោកជ្រាកដោយតណ្ហា និងទិដ្ឋិ ១( មើលភាគ ១៩ ទំព័រ ១៦១ ព្រះត្រៃបិដក ) ។

មានសេចក្តីពិស្តារដូចអរិយធម៌ដែរ ។

ង. អរិយវោហារ សំឡេងពោលចរចារផ្អែមល្ហែមពិរោះពិសារបស់អរិយជន បានដល់វចីសុចរិតទាំង ៤ មានមិនពោលកុហកជាដើម ឬ សុភាសិតផ្សេងៗ ដែលមានសារវ័ន្តដ៏ប្រសើរ ដោយកល្យាណវាចា មិនមានទោសសព្វអន្លើ ។

ច. អនរិយវោហារ ( មើលភាគ ១៩ ទំព័រ ១៧០ ព្រះត្រៃបិដក ) ។

សំឡេងពោលចរចាមិនផ្អែមល្ហែម មិនពីរោះពិសា មិនមែនជារបស់អរិយជន ផ្ទុយនឹងវចីសុចរិត ព្រមទាំងសុភាសិតផ្សេងៗ ។

ឆ. អរិយទ្រព្យ ទ្រព្យប្រសើរ ចោរលួចយកមិនបាន ភ្លើងឆេះមិនកើត ទឹកជន់ពន្លិចពុំបាន បច្ចាមិត្រដណ្តើមយកមិនបាន, បានដល់ទ្រព្យ ៧ ប្រការ មានសទ្ធាជាដើម ។

ជ. អារ្យប្រទេស ស្រុកកំណើត ទឹកដី ទីនៅ ប្រទេសតូចធំ ដែលមានរបៀបបទរៀបរយល្អ មានថ្នល់ផ្សារទូលំទូលាយ មានមនុស្សច្រើនកុះករ សុទ្ធតែអ្នកមានទ្រព្យ អ្នកចេះដឹង ដូចប្រទេសតណ្ឌៀជំនាន់ពុទ្ធកាល នឹងកោះសិរីលង្កាជំនាន់សតវត្សទី ៣ នៃពុទ្ធសករាជ គេតែងហៅថា អារ្យប្រទេស ។

ឈ. អារ្យជាតិ ជាតិអារ្យៈ ដូចព្រះបរមគ្រូជាម្ចាស់នៃយើងព្រះអង្គជាអារ្យជាតិ ។

សេចក្តីបំព្រួញថា ប្រទេសជាតិមាតុភូមិ ឬ បុគ្គលដទៃក្រៅអំពីន័យដូចខាងលើនេះមិនមែនឈ្មោះថា អរិយៈទេ ។ ដូចរឿងព្រានសន្ទូចម្នាក់ក្នុងក្រុងសាវត្ថី ព្រាននោះបានឃើញព្រះបរមសាស្តាទ្រង់ត្រាស់សួរព្រះសារីបុត្រថា លោកឈ្មោះអ្វី? ខ្ញុំព្រះអង្គឈ្មោះសារីបុត្តហើយទ្រង់ត្រាស់សួរព្រះមោគ្គល្លានថា លោកឈ្មោះអ្វី? ខ្ញុំព្រះអង្គឈ្មោះមោគ្គល្លាន ដូច្នេះជាដើម លោកទាំងនោះ សុទ្ធតែជាព្រះអរិយៈវិសេស ។ ព្រានក៏នឹកថា ប្រហែលជាព្រះបរមសាស្តាទ្រង់ត្រាស់សួរអញដែរមើលទៅ ។ ព្រះសម្ពុទ្ធទ្រង់ជ្រាបវារៈចិត្តរបស់ព្រានហើយទ្រង់ត្រាស់សួរថា នែឧបាសក! អ្នកឯងឈ្មោះអ្វី? ព្រានសន្ទូចឆ្លើយភ្លាមថា ខ្ញុំព្រះអង្គឈ្មោះអរិយៈ ។ ព្រះសម្ពុទ្ធទ្រង់បដិសេធថា នែឧបាសក! មិនមែនទេ មនុស្សប្រព្រឹត្តអំពើ

បាណាតិបាតដូចអ្នកយ៉ាងនេះ មិនមែនឈ្មោះថា អរិយៈទេ រួចហើយទ្រង់សំដែងគុណព្រះអរិយៈជាបទគាថាថា :

**ន តេន អរិយោ ហោតិ យេន បាណានិ ហឹសតិ**

**អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ ។**

( ធម្មបទដ្ឋកថា អរិយពាលិសិកវត្ថុ ភាគ ៧ ទំព័រ ៨៤ )

ប្រែថា បុគ្គលបៀតបៀនធ្វើសត្វឲ្យវិនាស មិនមែនឈ្មោះថា អរិយ ព្រោះការបៀតបៀននោះទេ ការមិនបៀតបៀនធ្វើសត្វឲ្យវិនាស ទើបហៅថា អរិយៈបាន ។

ពាក្យប្រែ ព្រមទាំងសេចក្តីអធិប្បាយអំពីអរិយស័ព្ទ នឹង ឧទាហរណ៍ប្រៀបធៀប ដែលនាំមកត្រួសៗនេះ ក៏ល្មមសមគួរដល់វេលាតែប៉ុណ្ណេះ ។

បន្ទាប់អំពីនេះ សូមផ្សាយកុសលរាសី ធម្មបណ្ណាការ ដ៏មានរសប្លែកនេះ ចែកជូនចំពោះទេវនិករក្នុងស្ថានសួគ៌ នឹងទេវនិករក្នុងស្ថានមនុស្ស ព្រមទាំងមនុស្សនិករមានព្រះបរមក្សត្រជាប្រធាន ដរាបដល់សត្វនិករ សូមឲ្យបានសម្រេចតដ្ឋមនុញ្ញផលសមតាមប្រាថ្នា មានសម្បត្តិព្រះនិព្វានជាអវសានកុំបីឃ្លាតឡើយ ។